**BMI0025**

# សម្ភាសន៍ជាមួយឈ្មោះ សៅ ណាំ ភេទប្រុស

មុខងារសម័យខ្មែរក្រហមៈ កងចល័ត

មុខងារបច្ចុប្បន្នៈ ទាហានសក្តិ២

ស្រុកកំណើតនៅភូមិ ឃុំស្នាច់ដែន ស្រុកព្រៃនប់ ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឆាយ ឈុនលី

០០:៤២:៤៤ និង ០០:០១:៣១

២៥ទំព័រ

ឈុនលី : ពូខ្ញុំឈ្មោះឈុនលី ខ្ញុំចង់សួរពូឈ្មោះអីដែរ ហើយខ្ញុំសុំឲ្យពូជួយរៀបរាប់ដូចថា ពូកើតនៅណាអីចឹង ឪពុកម្តាយធ្វើអី ព្រោះមិញសម្ភាសន៍ចេះសួរៗពូទៅ តែឥឡូវចង់ថតសម្លេង។

ណាំ : បាទ! ខ្ញុំឈ្មោះ សៅ ណាំ។

ឈុនលី : កើតនៅណា?

ណាំ : កើតនៅភូមិ.... ឃុំស្នាច់ដែន ស្រុកព្រៃនប់ ខេត្តកំពត។

ឈុនលី : ស្រុកព្រៃនប់?

ណាំ : ខេត្តកំពត។

ឈុនលី : ខេត្តកំពតទេ?

ណាំ : បាទ!

ឈុនលី : ចុះមិនមែនកំពង់សោមទេ?

ណាំ : អត់ទេ សម័យនោះកំពត។

ឈុនលី : ឪពុកម្តាយពូគាត់ឈ្មោះអី ហើយគាត់ធ្វើអី?

ណាំ : ឪពុកម្តាយខ្ញុំឈ្មោះ ង៉ោ ផាន់។

ឈុនលី : ឪពុកហ៎?

ណាំ : បាទ! ឪពុក។

ឈុនលី : ឈ្មោះអីគេ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ណាំ ៖ ង៉ោត ដាន់ ហើយម្ដាយឈ្មោះយាយស៊ីម ហើយនៅស្រុកកំណើតនៅភូមិ...ឃុំស្នាច់ដែន ស្រុកព្រៃនប់ ខេត្តកំពតដែរ ។

ឈុនលី ៖ គាត់មុខរបរធ្វើអីពូ?

ណាំ ៖ ធ្វើស្រែចំការ គាត់ធ្វើស្រែ ។

ឈុនលី ៖ ចុះពូមានបងប្អូនប៉ុន្មាននាក់?

ណាំ ៖ ខ្ញុំមានបងប្អូន៣នាក់ ។

ឈុនលី ៖ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ណាំ ៖ ស្រី២ ប្រុស១ ។

ឈុនលី ៖ ស្រី២ ប្រុស១?

ណាំ ៖ បាទ!

ឈុនលី ៖ ពូកូនទីប៉ុន្មាន?

ណាំ ៖ ខ្ញុំកូនទី២ ។

ឈុនលី ៖ ហើយដូចកាលនោះពូ ចឹងពូកើតឆ្នាំណា?

ណាំ ៖ ១៩៥៨ ។

ឈុនលី ៖ ៥៨ ដល់ពេលពូប្រហែលអាយុ១០ឆ្នាំអីដូចខ្ទង់៦០ជាង ឆ្នាំ៦០ជាង?

ណាំ ៖ បាទ!

ឈុនលី ៖ ហ្នឹងពូនៅធ្វើអីទៅ?

ណាំ ៖ ខ្ញុំនៅរៀន ។

ឈុនលី ៖ នៅរៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

ណាំ ៖ បានត្រឹមថ្នាក់ទី១១ចាស់ ។

ឈុនលី ៖ ថ្នាក់ទី១១ចាស់?

ណាំ ៖ បាទ!

ឈុនលី ៖ ស្មើនឹងថ្នាក់ទីប៉ុន្មាន?

ណាំ ៖ នេះស្មើនឹងថ្នាក់ទីប៉ុន្មាន ស្មើនឹងថ្នាក់ទី៣នេះដឹង ហើយក្រោពីនឹងមកនៅជួយធ្វើការងារម្ដាយឪពុកម្ដាយ ។

ឈុនលី ៖ ការងារអីខ្លះ?

ណាំ ៖ ធ្វើស្រែ ។

ឈុនលី ៖ ភ្ជួររាស់អីចឹងទៅ?

ណាំ ៖ បាទ! ភ្លូរពាស់ ។

ឈុនលី ៖ ហើយចុះអាក្នុងកំឡុង៧៥នឹងនោះពូថានៅធ្វើការនៅកងចល័តនៅអី?

ណាំ ៖ បាទ! ធ្វើការ ។

ឈុនលី ៖ ចាប់ផ្ដើម៧៥ ពូអត់មានគេជម្លៀសទៅណា?

ណាំ ៖ អត់ទៅណាទេ ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ ខ្ញុំ៧៥នឹងនៅក្នុងស្រុក នៅក្នុងប្រទេសដែរតើ អត់មានទាន់នៅក្នុងស្រុកដែរ គេអត់ទាន់ជម្លៀស គេអត់ដែលថាជម្លៀសផង ៧៥អត់មានជម្លៀសចេញ ។

ឈុនលី ៖ នៅនឹង?

ណាំ ៖ បាទ! នៅនឹង ។

ឈុនលី ៖ ហើយពូធ្វើការដូចអីខ្លះទៅ?

ណាំ ៖ ធ្វើស្រែ ជួយភ្ជួរស្រែម្ដាយឪពុកហ្នឹង ។

ឈុនលី ៖ អត់ទេ និយាយថាក្នុងសម័យខ្មែរក្រហមម៉ង ៧៥ ៧៦ ៧៧?

ណាំ ៖ អត់បានធ្វើអីទេ ធ្វើតែកងចល័ត ។

ឈុនលី ៖ ធ្វើកងចល័ត?

ណាំ ៖ បាទ!

ឈុនលី ៖ ធ្វើការម៉ាកន្លែង ឬកចល័តទៅណាទៅណៃ?

ណាំ ៖ មកចល័តមកធ្វើនៅស្រុកព្រៃទប់ ជីកប្រឡាយជីកអីតាមនឹង ។

ឈុនលី ៖ មានបងប្អូនណាគាត់ធ្វើជាមួយ?

ណាំ ៖ អត់ទេ ។

ឈុនលី ៖ បងប្អូនរបស់ពូ?

ណាំ ៖ បងប្អូនខ្ញុំនៅតូចៗនឹង មកនៅជម្លៀសមកនៅស្រុកព្រៃទប់នឹង ឪពុកម្ដាយខ្ញុំមកនៅនឹងព្រៃទប់ឆ្នាំ៧៥នៅនឹងជុំគ្នាទាល់តែឆ្នាំ៧៩ទេ ។ ឆ្នាំ៧៩គាត់រត់បែកគ្នាគាត់ គេថាអ៊ំ! វៀតណាមចូលមកខ្ញុំរត់បែកម្ដាយឪពុកខ្ញុំ ខ្ញុំនៅកងចល័តនឹង ឪពុកម្ដាយខ្ញុំគាត់រត់ចូលទៅស្រុក ទៅកំពង់សោមវិញ ។ ហើយខ្ញុំក៏មកតាមអង្គភាពកងចល័តនឹងក៏គេឲ្យមកចូលមកខាងព្រំដែនអីទាំងអស់ ។ ដល់ចឹងក៏បែកគាត់តាំងពីនឹង តាំងពី៧៩ដូចខ្ញុំថា ។

ឈុនលី ៖ ចុះពូនៅពេលនៅកំឡុង៣ឆ្នាំនឹង នៅតែនឹងទេ?

ណាំ ៖ នៅតែនឹង ។

ឈុនលី ៖ ហើយចឹងម៉េចបានពូរត់មកដល់នេះ?

ណាំ ៖ ចុះកាល៧៩ ខ្ញុំមិននៅកងចល័តៗ គេមានមេគេគ្រប់គ្រង ។

ឈុនលី ៖ មេគេឈ្មោះអី?

ណាំ ៖ មេគេខ្ញុំភ្លេចបាត់ហើយ យូរដែរ មិនដឹងបែកគ្នាទៅណាទៅណៃ ។

ឈុនលី ៖ ស្រី ហើយប្រុស ពូមេគេនឹង?

ណាំ ៖ ប្រុស តែពេលនឹងគេឲ្យប្រមូលរត់មកទាំងអស់ មកជាយដែនទាំងអស់ កងចល័ត ។

ឈុនលី ៖ គេឲ្យមកជាយដែន?

ណាំ ៖ បាទ! គេឲ្យមកជាយដែន ។

ឈុនលី ៖ ពូដឹងទេ ភាគច្រើនមកពីខេត្តណាខ្លះទៅ?

ណាំ ៖ គ្រប់ខេត្ត ។

ឈុនលី ៖ ហើយអ្នកខ្លះក៏គេអត់មកតាមជាយដែននេះទេ?

ណាំ ៖ ខ្លះក៏អត់ ខ្លះក៏មក បើអ្នកមានកងឈ្មោះថាកងចល័តមានមេក្រុមមេកងគេនឹង ដឹងតែមកម៉ង មកភាគច្រើនម៉ង មកព្រំដែន ។

ឈុនលី ៖ ចា៎! ៧៩ ។ ចុះកងពូមានប៉ុន្មាននាក់ទៅ?

ណាំ ៖ កងខ្ញុំច្រើនណាស់ មាន១០០នាក់នឹងកាលនឹងម៉ាកងធំគេហៅម៉ាកងធំ ខ្ញុំនៅតូចៗមិនសូវដឹងទេ តាមតែគេបង្ៗ ។

ឈុនលី ៖ ដល់ពេលមក៧៩មកដល់នឹង?

ណាំ ៖ បាទ! មកដល់នឹង ។

ឈុនលី ៖ ចូលព្រៃបណ្ដោយ?

ណាំ ៖ បាទ! ចូលព្រៃបណ្ដោយនៅជាមួយខ្មែរក្រហមបណ្ដោយ ។

ឈុនលី ៖ ចុះហេតុអីបានពូអត់រត់គេចទៅណាផ្សេងទៀត?

ណាំ ៖ អត់ទៅណាកើតព្រោះគេឲ្យមកចឹងមក ចេះមកតាមគ្នា ។

ឈុនលី ៖ អត់រួចរត់?

ណាំ ៖ បាទ! មកទាំងរ៉ូងមក គេឲ្យមកច្រើន មកទាំងអង្គភាព មកទាំងកង ទាំងស្រីទាំងប្រុស ។

ឈុនលី ៖ ពូស្គាល់ប្រធានអង្គភាពកន្លែងកងពូ អត់?

ណាំ ៖ អត់ទេ ខ្ញុំភ្លេចបាត់ហើយ ផ្លាស់ប្ដូរច្រើនពេកមិនដឹងណាណៃខ្ញុំភ្លេច ។

ឈុនលី ៖ ហើយដល់ពេលមកដល់នេះ៧៩ អឺ!មកដល់ណាភ្លាមទៅ យើងអាច?

ណាំ ៖ មកដល់នឹងមកដល់នេះ មកដល់ខ្សែម ។

ឈុនលី ៖ ខ្មែម?

ណាំ ៖ បាទ! ខ្មែម កំរៀងយើង ។

ឈុនលី ៖ ខ្មែមខាង បាត់ដំបង ហើយនៅបន្ទាយមានជ័យ?

ណាំ ៖ បាទ! ហ្នឹងបាត់ដំបង ។

ឈុនលី ៖ នៅនឹងធ្វើអីទៀតពូ?

ណាំ ៖ នៅនឹងមកដល់នៅធ្វើខ្មែរក្រហមនឹងឯង ។

ឈុនលី ៖ ធ្វើខ្មែរក្រហមនឹង ពូតួនាទីពូធ្វើអី?

ណាំ ៖ ធ្វើយុទ្ធជន.... ។

ឈុនលី ៖ ចាប់ផ្តើមចូលទាហានខ្មែរក្រហមបណ្តោយ៧៩នឹង?

ណាំ ៖ បាទ! ចូលធ្វើទាហានខ្មែរក្រហម ។

ឈុនលី ៖ ហើយពេលនឹងច្បាំងគ្នាទេ?

ណាំ ៖ ច្បាំងតើ តែមិនទាន់ច្បាំងខ្លាំងទេ អត់ទាន់ច្បាំងទេ ឆ្នាំ៧៩ ។

ឈុនលី ៖ គេហាត់ៗរៀនទេ?

ណាំ ៖ ៨០គេហាត់ ៨០ ៨១ខ្ញុំនៅហាត់ គេឲ្យរៀន គេមិនឲ្យហាត់ទេ ។

ឈុនលី ៖ ចុះអ្នកណាធ្វើមេទាហាននៅនឹង?

ណាំ ៖ មកនឹងខ្ញុំថាមកនឹងនៅជាមួយវ៉ាន់ សុផាតៗមក បានឈឹម មុន្នី ។

ឈុនលី ៖ វ៉ាន់ សុផាតតួនាទីគាត់អីគេ?

ណាំ ៖ កាលនឹងគាត់នៅកងធំ ។

ឈុនលី ៖ កងលេខប៉ុន្មាន?

ណាំ ៖ ភ្លេចបាត់ហើយ អត់ចាំទេអារឿងកង ។

ឈុនលី ៖ ប្រធានកងម៉ង?

ណាំ ៖ បាទ! គាត់ប្រធានកង ខ្ញុំនៅយុទ្ធជននៅជាមួយគាត់ចេះកង ហើយចេះនៅរហូតៗមកនៅម៉ាឡៃនឹងបាន... ។

ឈុនលី ៖ ចុះពូថាឈឹម មុន្នីនោះ?

ណាំ ៖ ហ្នឹងហើយឈឹម មុន្នីនឹងជាមួយ ឈឹម មុន្នី ។

ឈុនលី ៖ បន្ទាប់ជាមួយផាត់នឹង?

ណាំ ៖ អត់ទេ ផាត់ហើយ បាន ឈឹម មុន្នី ។

ឈុនលី ៖ តួនាទីប្រហែលគ្នា ប៉ុន្តែផ្លាស់ប្តូរគ្នា?

ណាំ ៖ បាទ! ផ្លាស់ប្តូរ ។

ឈុនលី ៖ ចុះហេតុអីបានដូរជាតនឹង មកមុន្នីនេះវិញ?

ណាំ ៖ អត់ទេនៅជាមួយគ្នា ជាតនឹងមេក្រុមចិន គាត់នឹងមេកងតូចចិនទៅ គេធ្វើចិនគ្រប់គ្រងទាំងអស់គ្នា រហូតមកនៅ ។

ឈុនលី ៖ ពូចាំទេ កងពូមកនៅប៉ុន្មាននាក់?

ណាំ ៖ កងខ្ញុំនឹងនៅ១០០នាក់ ។

ឈុនលី ៖ កងទាហាននឹង១០០នាក់?

ណាំ ៖ បាទ! ១០០នាក់ ឈ្មោះកង៣៣ ។

ឈុនលី ៖ ចិនអាខ្ទង់៧៩នឹងអត់ទាន់ច្បាំងនៅណាទេចិន?

ណាំ ៖ នៅទេ ។

ឈុនលី ៖ ឆ្នាំណាបានចាប់ផ្តើមច្បាំង?

ណាំ ៖ ឆ្នាំ៨៣ ។

ឈុនលី ៖ ៨៣ច្បាំងនឹង ពូផ្លាស់មកនៅខាងនេះ?

ណាំ ៖ នៅម៉ាឡៃហើយ ។

ឈុនលី ៖ ចិនមកនៅម៉ាឡៃឆ្នាំណា?

ណាំ ៖ ៨៣ ។

ឈុនលី ៖ ចិនពីដំបូងមកនៅបាត់ដំបងនឹងទេ?

ណាំ ៖ បាទ! នៅបាត់ដំបង ។

ឈុនលី ៖ ស្រុកអី!

ណាំ ៖ ស្រុកអី!

ឈុនលី ៖ ពូថាស្រុកអី ខ្មែរ?

ណាំ ៖ កំរៀង ។

ឈុនលី ៖ អានឹងអ្នកគ្រប់គ្រងតំបន់ធំម៉េងណាគេទៅ?

ណាំ ៖ បាទៗ តំបន់ធំ ក្នុងនឹងអត់មានអ្នកណាគ្រប់គ្រងតំបន់ធំទេ មានតែក! ។

ឈុនលី ៖ ដូចតំបន់ជាយដែនចិន អ្នកណាគេអ្នកកាន់?

ណាំ ៖ បាទ! តំបន់ជាយដែនអត់ទាន់មាននេះអីទេ មានតំបន់ជាយដែនចិន ។

ឈុនលី ៖ អត់មានអ្នកណាគេកាន់ធំ?

ណាំ ៖ បាទ!អត់មាន ។ មានតែមេកងតាមលំដាប់លំដោយ នៅខាងគ្រាន់តែប៉ែកខាងនឹងមានលោក នី កន ប៉ែកខាងពីកំរៀងមកដល់សំពៅលូននឹង នី កន ។

ឈុនលី ៖ ពូចឹងក្រែងថាឆ្នាំ៨៣នឹង គេដាក់មីនដាក់អី?

ណាំ ៖ បាទ! អានឹងដាក់ហើយចាប់ផ្ដើមដាក់ហើយ ។

ឈុនលី ៖ តាំងពី៨០ប៉ុន្មានមកដាក់មីន?

ណាំ ៖ តាំងពីឆ្នាំ៨២មក ។

ឈុនលី ៖ ចុះអា៨១?

ណាំ ៖ ៨១អត់ទាន់ទេ ។

ឈុនលី ៖ រស់នៅធម្មតា?

ណាំ ៖ រស់នៅធម្មតា ។

ឈុនលី ៖ ចុះពូកាលដូច៧៩ ៨០ ៨១នឹង ពូធ្វើចាហានហ្នឹង ដូចហូបចុកអីម៉េចទៅ?

ណាំ ៖ ហូបចុកលំបាកណាស់ ។

ឈុនលី ៖ អត់មានអីហូប?

ណាំ ៖ បាទ! ៧៩ពិបាកការហូបចុក ។

ឈុនលី ៖ បានម្ហូបពីណាមក ស្បៀង?

ណាំ ៖ គេយកមកតាមលេខ១អង្គភាព យកមកមិនដឹងយកមកពីណាចេញពីស្រុកថៃមក ។

ឈុនលី ៖ អត់មានអី?

ណាំ ៖ បាទ!

ឈុនលី ៖ ដល់ពេល៨៣ដាក់មីន ខាងណាដាក់មីន?

ណាំ ៖ ខាងខ្ញុំនឹង ខាងខ្មែរក្រហមនឹង ។

ឈុនលី ៖ ចុះមីនខាងវៀតណាមអត់?

ណាំ ៖ អត់ទេ វៀតណាមដល់ឆ្នាំ៨៤ ។ខ្ញុំចូលទៅនឹង ៨៤នឹងពួកវៀតណាមវ៉ៃតាមជាយដែននឹង វ៉ៃពួករដ្ឋកម្ពុជាវ៉ៃហើយ ពួកខ្ញុំរត់ទៅចូលដីថៃ ។

ឈុនលី ៖ កងទ័ពទាំងអស់ទៅនៅដីថៃ?

ណាំ ៖ បាទ! កងទ័ពទាំងអស់ទៅនៅដីថៃ ។

ឈុនលី ៖ ហេតុអីចាំបាច់ទៅនៅដីថៃ?

ណាំ ៖ ព្រោះអត់មានកន្លែងដីនៅ ។

ឈុនលី ៖ ចុះគេមកចឹង ប៉ុន្តែគេមកចូលកើតដែរ បើយើងដាក់មីនដាក់អីចឹង?

ណាំ : ចូលកើតប៉ុនខ្លាចវើផង នៅតាមចំនុចៗនៅតាមចំនុចៗបេះរាវវៀតណាម...... ហើយខ្ញុំចូលទៅថៃ ។ ហើយក្រោយមកបានរត់ទៅនៅតាមចន្លោះៗដែលពួកវៀតណាម រដ្ឋកម្ពុជាដែលនៅចន្លោះៗ ។ ហើយខ្ញុំក៏ចូលទៅក្នុងទៀត ទៅនៅបន្ទប់ក្នុងនោះ ។ ចឹងហ៊ានអត់មាននៅតាមជាយដែនបានទេ កាលនឹងឆ្នាំ៨៤ ។

ឈុនលី : ចុះអាឡែងយើងចេញចឹងទៅចឹង មិនវៀតណាមចូលមកទេ?

ណាំ : ចូលៗដល់ក្រោយមក ចូលនៅនឹងតាមជាយដែនកាលនឹងឆ្នាំ៨៤ ។

ឈុនលី : តែនៅកន្លែងអាយើងដាក់មីនចឹង វាអត់មកទេ?

ណាំ : អត់ទេ អត់មកទេ នៅកន្លែងដែលយើងអត់ដាក់ វាចន្លោះៗ ។ ហើយពួកខ្ញុំនឹងក៏នៅតាមចន្លោះៗដែរ នៅតាមមាត់អូរតាមដីថៃចឹង នៅចន្លោះៗ ។ ហើយគេបេះឲ្យនៅ ដល់ពេលនេះវិញវើៗវិញ បានឆ្នាំ៨៦ ៨៧នឹងវើពួកវៀតណាមពួកខ្មែរនឹង រត់ចូលទៅក្នុងវិញ បានពួកខ្ញុំមកនៅតាមនេះតាំងពីឆ្នាំ៨៧ ។

ឈុនលី : ៨៧មកនៅនឹង?

ណាំ : បាទ! ៨៧ចូលដល់នេះវិញ ។

ឈុនលី : ចឹងវាឡើងប៉ុន្មានឆ្នាំ ៨៤មកដល់៨៧ នៅថៃ៣ឆ្នាំ?

ណាំ : ៣ឆ្នាំ ។

ឈុនលី : នៅណាជំរំនឹង?

ណាំ : គេហៅជំរំតាឌុំក ។

ឈុនលី : ចុះជំរំ៨៥ ?

ណាំ : ហ្នឹងហើយជំរំ៨៥នឹង តាឌុំក ។

ឈុនលី : ជំរំ២នឹងខុសគ្នាម៉េច?

ណាំ : ខុសគ្នា ៨៥នៅជ្រៅ ។

ឈុនលី : តាឌុំកនឹងនៅជិត?

ណាំ : បាទ!

ឈុនលី : ហើតពេលនឹងថៃមានចូលមកដីខ្មែរ?

ណាំ : អត់ទេ អត់មកទេ ហើយអត់មានទៀត ខ្ញុំនៅជំរំ៨៥អានឹងកន្លែងកងទ័ពនៅ ។

ឈុនលី : ចុះជួបមីង?

ណាំ : ហ្នឹងការៗឆ្នាំ៨៥នឹងឯង ។

ឈុនលី : នៅក្នុងជំរំ?

ណាំ ៖ នៅក្នុងជំរំដីថៃ ។

ឈុនលី ៖ ស្គាល់គ្នានៅថៃ?

ណាំ ៖ បាទ!

ឈុនលី ៖ ចុះមីងមកតាមរយៈអីដែរ?

ណាំ ៖ គាត់នៅខាងដឹកជញ្ជូន កាលនឹងគាត់មកតាមកងចល័តដូចគ្នា ដូចខ្ញុំថាមកជាកង១ស្រី១នៅខាងដឹកជញ្ជូន ដល់មកចឹងគេឲ្យនៅខាងដឹកជញ្ជូន១គ្រាប់ ដឹកជញ្ជូនអី១ឲ្យកងទ័ពនឹង ដល់នឹងទៅជុំគ្នាហ្នឹង១បានខ្ញុំរៀបការជាមួយគាត់នឹង នៅជំរំ៨៥ ។ មែនទែន៨៤ ៨៥ខ្ញុំការទៅនៅបានម៉ាឆ្នាំ ខ្ញុំការ ។

ឈុនលី ៖ ពេល៨៧ត្រឡប់មកវិញ?

ណាំ ៖ បាទ! ៨៧ត្រឡប់មកវិញ ។

ឈុនលី ៖ ហើយដីសុទ្ធមីននោះ ម៉េចទៅ?

ណាំ ៖ មកនឹងមកដំបូងបន្ទស់ចេញពីដីថៃ ដឹកមកចុះតាមនេះឯង ខ្ញុំនៅនឹងម៉ង មកដល់នៅដីនឹង ធ្វើផ្ទះនៅនឹង ។

ឈុនលី ៖ មានមីនអត់?

ណាំ ៖ មាន ។

ឈុនលី ៖ ហើយធ្វើម៉េចទៅ?

ណាំ ៖ ដោះ ។

ឈុនលី ៖ អ្នកណាអ្នកដោះ?

ណាំ ៖ ខ្ញុំចេះរាវដោះទៅ ដោះខ្លួនឯង ។

ឈុនលី ៖ រាវម៉េចទៅ?

ណាំ ៖ រាវ អ្នកណាមានខ្សែយើងដោះ អ្នកណាមាន ។

ឈុនលី ៖ ធ្វើម៉េចដឹង?

ណាំ ៖ ដឹង ពូធ្លាប់ធ្វើកងទ័ព ពូដឹងច្បាស់ ។

ឈុនលី ៖ ម៉េចទៅពូអាចប្រាប់បានទេ?

ណាំ ៖ ដូចថាមីន៦៩ចិននឹង គេដាក់វាមានខ្សែវា ។

ឈុនលី ៖ ខ្សែយើងមើលម៉េចដឹង?

ណាំ ៖ ខ្សែវាប៉ុននេះដាក់កប់ដី មិនដាក់កប់ដីដាក់ដូចដបចឹង ដាក់ប្រឡាំៗគេដាក់ខ្សែចេះមក យើង ឃើញយើងចាប់ផ្ដើមរាវវាទៅ យើងមកយើងដោះម្ជុរវាចេញ យកចេញដោះម្ជុរចេញ យកចេញ ។

ឈុនលី ៖ ដោះម្ជុរចេញទៅយកចេញបាន?

ណាំ ៖ បាទ! យកចេញបាន ។

ឈុនលី ៖ អូរ!វាមានម្ជុរតូចនៅនឹង?

ណាំ ៖ បាទ! វាមានម្ជុរតូចសម្រាប់វ៉ៃគឹបវា អាពេលនេះខ្ញុំទៅដោះយកដៃដោះចឹងទៅ ។

ឈុនលី ៖ អត់ខ្លាចៗ?

ណាំ ៖ ខ្លាចដែរ តែប៉ុនចេះវាធ្លាប់ហើយ ។

ឈុនលី ៖ ប្រថុយ?

ណាំ ៖ បាទ! ប្រថុយ បើមីនស្កូរ អាមីនកប់ដីមីនស្កូររបស់ចិន អានឹង...យើងរាវវាដឹង ឃើញ ដល់ដឹងចំនុចវាបានដោះបាន ប៉ុនឃើញស្រួលដោះដាង ។

ឈុនលី ៖ មីនគេចងខ្សែ មានម្ជុរហើយ គេចងខ្សែទៀត?

ណាំ ៖ បាទ! ចងខ្សែខៀវមើលអត់ឃើញប្រឡោះប៉ុនៗនេះ អានឹងដើរទាក់ចូលក្នុងនឹងមានតែម៉ា គ្រាប់នឹងដើរគ្នា៩នាក់ ងាប់ទាំង៩នាក់ របួស អឺ!ងាប់យ៉ាងហោចណាស់ក៏៣ ។

ឈុនលី ៖ អាខ្សែនឹងតែទាក់ផ្ទុះ?

ណាំ ៖ បាទ! ផ្ទុះ បើមិនងាប់៣ទៅ២ មីនអំបែងខ្លាំងណាស់ របស់៦៩របស់ចិន ។

ឈុនលី ៖ ចុះនៅតំបន់នេះខ្មែរក្រហមភាគច្រើនដាក់មីនអី?

ណាំ ៖ ដាក់មីន៦៩របស់ចិន ហើយនឹងមីនស្កូររបស់ចិន ។

ឈុនលី ៖ ចុះមីនស្នូលពោត មីនគោនមីនអី?

ណាំ ៖ មីនស្នូលពោតនឹងមីនរបស់វៀតណាម របស់រដ្ឋកម្ពុជា ។

ឈុនលី ៖ ចុះអាគោន?

ណាំ ៖ មីនគោនរបស់ចិន... ។

ឈុនលី ៖ ដឹកជញ្ជូនមករហូតម៉ង?

ណាំ ៖ បាទ! ស្រើៗដឹកជញ្ជូនមករបូត ។

ឈុនលី ៖ ដឹកមកតាមណា?

ណាំ ៖ មិនដឹងកាលនឹងដឹកមក ដឹងដឹកតាមណា ឃើញតែគេឲ្យទូលគ្រាប់មកដល់ព្រំដែនឃើញតែ គ្រាប់ ។

ឈុនលី ៖ ពូដែលដាក់មីនដែរ?

ណាំ ៖ ខ្ញុំដែរ ខ្ញុំដាក់។

ឈុនលី ៖ ចឹងបានន័យថាមុននឹងទៅថៃនឹង ពូក្រុមខាងទ័ពពូអ្នកដាក់មីន?

ណាំ ៖ បាទ!ដាក់មីន។

ឈុនលី ៖ មកវិញដោះចេញខ្លួនឯង?

ណាំ ៖ បាទ! ហ្នឹងហើយធ្លាប់ដាក់។

ឈុនលី ៖ ចឹងបានដឹងកន្លែង?

ណាំ ៖ ដឹងតើ ទៅចឹង។

ឈុនលី ៖ ចុះពូពេលមកនៅនឹងមានទាហានខ្មែរក្រហម ហើយទាហានខាងណាទៀតដែលនៅទឹកដីខាង ម៉ាឡៃហ្នឹង?

ណាំ ៖ កាលនឹងមកនឹងមានតែខ្មែរក្រហមហើយនឹងរដ្ឋកម្ពុជា។

ឈុនលី ៖ ខ្មែរក្រហម រដ្ឋកម្ពុជា?

ណាំ ៖ បាទ!

ឈុនលី ៖ ចឹងបានន័យថា២បក្សនឹងនៅជាមួយគ្នា?

ណាំ ៖ អត់ទេ នៅឆ្ងាយពីគ្នាចឹង ដូចខ្មែរក្រហមនៅព្រំដែន រដ្ឋកម្ពុជានៅដូចម្តុំកូនដំរី។

ឈុនលី ៖ ឆ្ងាយ?

ណាំ ៖ បាទ! ឆ្ងាយពីគ្នា។

ឈុនលី ៖ ហើយទំនាក់ទំនងគ្នាអត់?

ណាំ ៖ អត់ទំនាក់ទំនងទេ។

ឈុនលី ៖ ឈ្លោះគ្នាដែរ?

ណាំ ៖ បាទ! ឈ្លោះគ្នា។

ឈុនលី ៖ ចឹងបានន័យថាក្រុមរដ្ឋកម្ពុជានឹង មកនឹងមកប្រឆាំងជាមួយខ្មែរក្រហមទេ?

ណាំ ៖ បាទ! មកប្រឆាំងទេ វ៉ៃគ្នា។

ឈុនលី ៖ ហើយរដ្ឋកម្ពុជានឹងដាក់មីនដែរអត់?

ណាំ ៖ ដាក់ៗដូចគ្នា។

ឈុនលី ៖ ចឹងបានន័យថាខ្មែរក្រហមនៅនឹង ហើយរដ្ឋកម្ពុជានៅខាងកូនដំរី?

ណាំ ៖ បាទ! កូនដំរី។

ឈុនលី ៖ ហើយបើដាក់' មីនចឹង ដាក់កន្លែងណាទៅខាងនោះ?

ណាំ ៈ ដាក់តាមកន្លែងបន្ទាយគេៗ នៅកន្លែងគេដាក់ជុំវិញបន្ទាយគេ ។

ឈុនលី ៈ ដាក់ជុំវិញអត់ឲ្យយើងចូល?

ណាំ ៈ បាទ! អត់ឲ្យខ្មែរក្រហមចូល ។

ឈុនលី ៈ ពូចុះដល់ពេលមកពីថៃចឹង ព្រៃនៅតែមានចឹង សុទ្ធតែព្រៃមែនអត់?

ណាំ ៈ សុទ្ធតែព្រៃ តាមនេះព្រៃទាំង ។

ឈុនលី ៈ ហើយដល់ពេលចឹងយើងមកដល់នឹងចាញ់ទៀត មកពីថៃចាញ់ទៀត?

ណាំ ៈ ចាញ់ គ្រូនចាញ់ ។

ឈុនលី ៈ ហើយចឹងធ្វើម៉េចទៅ?

ណាំ ៈ ខ្ញុំអត់មានធ្វើម៉េចទេ មានតែព្យាបាល ។

ឈុនលី ៈ បានអី ថ្នាំយកមកពីណា?

ណាំ ៈ ថ្នាំមិនដឹងមកពីណា គេអង្គភាពមេអង្គភាពគេយកមកឲ្យ ។

ឈុនលី ៈ អាពេលមកពីថៃមកទាំងអស់?

ណាំ ៈ បាទ! មកទាំងអស់ ។

ឈុនលី ៈ ហើយក៏មានអ្នកមកមុនមកក្រោយ?

ណាំ ៈ អត់ទេ មកទាំងអស់គ្នា? ។

ឈុនលី ៈ ចុះមានអ្នកខ្លះមកតាំង៨៥ នៅមកតាំងពីឆ្នាំ៨៥?

ណាំ ៈ អត់មានទេ ។

ឈុនលី ៈ ហើយចឹងចុះពេលមកនៅនឹងភ្នាមចឹង ផ្ទះសម្បែងបានអីនៅ?

ណាំ ៈ ធ្វើផ្ទះតូចៗ នៅផ្ទះស្បូវ ។

ឈុនលី ៈ ធ្វើស្បូវ?

ណាំ ៈ បាទ! ធ្វើស្បូវនៅតូច ។

ឈុនលី ៈ ចឹងមកដល់មិននាំគ្នាក្រងស្បូវក្រងអី?

ណាំ ៈ បាទ! ក្រងស្បូវក្រងអី ប្រពន្ធខ្ញុំក្រងស្បូវ ។

ឈុនលី ៈ ហើយប្តីពេលមកចឹង ឈប់ទៅច្បាំងទៀតហើយ?

ណាំ ៈ បាទ! ទៅមកៗទៅ ។

ឈុនលី ៈ ហើយដូចជាបានតង់បានអីពីគេធ្វើមកអត់ធ្វើផ្ទះ នៅបាំងតង់?

ណាំ ៈ មានតង់កៅស៊ូខៀវៗតូចៗនោះ ។

ឈុនលី ៈ ហើយចុះស្បៀងនោះ?

ណាំ ៖ ស្បៀងខាងមេអន្តភាពគេដោះស្រាយឲ្យ ។

ឈុនលី ៖ ចែកឲ្យរហូត?

ណាំ ៖ បាទ!

ឈុនលី ៖ កាលនឹងពូមានកូន អត់ទាន់មានកូន?

ណាំ ៖ មានកូន២នាក់ហើយ តែតូចៗ ។

ឈុនលី ៖ ពេលមកហ្នឹង?

ណាំ ៖ បាទ!

ឈុនលី ៖ ចឹងបានន័យថាកូន២នាក់ហ្នឹង ចាប់កំណើតនៅថៃ?

ណាំ ៖ បាទ!

ឈុនលី ៖ កើតលើទឹកដីថៃ?

ណាំ ៖ ...កើតប៉ុន្មានខែមក...... ហើយមីបងអាយុម៉ាខួបកន្លះ ។

ឈុនលី ៖ ចុះដល់ពេលយើងមកហើយចឹង ទាហានរដ្ឋកម្ពុជានៅនឹងដដែលទៀត?

ណាំ ៖ អត់ទេ ថយទៅអស់ហើយ ថយទៅនៅក្នុងៗអស់ ។

ឈុនលី ៖ ចុះឆ្នាំណាបានវៃបាន ពួកវៀតណាមរត់ចេញ?

ណាំ ៖ ហ៉េ! អត់ទេ ហ្នឹងអត់មានរត់ទេ ហ្នឹងចប់ហើយវៀតណាមចប់ហើយ ។

ឈុនលី ៖ ពេលយើងមកពីថៃវិញ ឈប់អស់មានវៀតណាម?

ណាំ ៖ អស់មានហើយ អត់មានទេ ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ វៀតណាមទៅអស់ហើយ ។

ឈុនលី ៖ ម៉េចបានទៅ?

ណាំ ៖ មិនដឹង នៅតែខាងខ្មែរទាហានខ្មែរ ទាំងសងខាង ។

ឈុនលី ៖ ចុះយើងនៅច្បាំងៗជាមួយអ្នកណាទៀត?

ណាំ ៖ ច្បាំងជាមួយខ្មែរ ទាហានខាងរដ្ឋកម្ពុជា ។

ឈុនលី ៖ ចឹងបានន័យថាខ្មែរក្រហមត្រូវវៃជាមួយបក្ស២បក្សមែនអត់?

ណាំ ៖ ហ្នឹងហើយ ២បក្ស ។

ឈុនលី ៖ ជាមួយរដ្ឋកម្ពុជាផង ជាមួយវៀតណាមផង?

ណាំ ៖ បាទ! ហ្នឹងហើយ ។

ឈុនលី ៖ ដល់ពេលវៀតណាមរត់អស់ទៅ យើងវៃជាមួយរដ្ឋកម្ពុជា?

ណាំ ៖ បាទៗ ។

ឈុនលី ៖ វៃរហូតដល់ឆ្នាំណា?

ណាំ ៖ រហូតដល់ឆ្នាំ៩៨ ។

ឈុនលី ៖ ៩៨នឹងអស់រដ្ឋកម្ពុជាទៀត?

ណាំ ៖ ៩៨អត់ទាន់អស់ទេ ដល់គេមកចចារគ្នាសមាហរណកម្មនឹង ៩៨ ៩៥នឹង ។

ឈុនលី ៖ កំពុងតែចចារ?

ណាំ ៖ ចចារគ្នាទៅ ។

ឈុនលី ៖ ចុះដល់ពេល៩៦?

ណាំ ៖ ៩៦ចប់ ។

ឈុនលី ៖ ចប់មែនទែនហើយ?

ណាំ ៖ បាទ!

ឈុនលី ៖ អានឹងពេលសម្តេចមក?

ណាំ ៖ បាទ!

ឈុនលី ៖ ៩៦ ហើយ៩៧?

ណាំ ៖ ៩៧ ។

ឈុនលី ៖ ចឹង៩៨ ៩៥ ៩៦កំពុងចចារ?

ណាំ ៖ បាទ! កំពុងចចារគ្នា ។

ឈុនលី ៖ ហើយពូនៅតែទៅបន្ទាយទៅអីដែរ?

ណាំ ៖ នៅៗច្រើននៅតាមកន្លែង នៅតាមកន្លែងកងគេ ។

ឈុនលី ៖ ហើយគេនៅតែខបត្តម្ភចឹងទៀត?

ណាំ ៖ បាទ! គេនៅខបត្តម្ភ ការហូបចុករបូត ។

ឈុនលី ៖ ហើយចុះដល់ពេលបន្ទាប់ពីសមាហរណកម្មនឹង ពូធ្វើទាហានទៀត?

ណាំ ៖ ហ្នឹងធ្វើទាហានរបូតនៅជាមួយរដ្ឋកម្ពុជា ។

ឈុនលី ៖ រហូតដល់ពេលយើងចចារត្រូវគ្នា យើងធ្វើទាហានជាមួយគ្នាទាំងខ្មែរក្រហមទាំងអី?

ណាំ ៖ ធ្វើទាល់តែរហូតឥឡូវមិនទាន់ឈប់ផង នៅ៥១ កងពល៥១ ។

ឈុនលី ៖ ពូអ្នកណាអ្នកដឹកនាំចចារនៅតំបន់នឹង?

ណាំ ៖ មានអ៊ីអៀង សារី ។

ឈុនលី ៖ អូ! គាត់គ្រប់គ្រងធំនៅនេះ?

ណាំ ៖ បាទ!

ឈុនលី ៖ ចុះក្រែងប៉ៃលិននោះ គាត់នឹងដែរ?

ណាំ ៖ ទាំងអស់នៅតាមជាយដែន ។

ឈុនលី ៖ ចឹងបាននិ័យថាគាត់គ្រប់ពីតំបន់ណាមក?

ណាំ ៖ ចាប់ពីតំបន់ម៉ាឡៃហើយប៉ៃលិន ។

ឈុនលី ៖ ចុះតាអីគេ?

ណាំ ៖ តាម៉ុក ។

ឈុនលី ៖ ចុះអីគេខៀវ សំផន អីគាត់នៅណា?

ណាំ ៖ ខៀវ សំផន គាត់នៅជាមួយគាត់ សាខាជាមួយគ្នាគាត់ ខ្ញុំអត់ដឹងមិនសូវដឹង ។

ឈុនលី ៖ ចុះប្រពន្ធអៀង សារី?

ណាំ ៖ ប្រពន្ធអៀង សារីគាត់មិនដែលដឹងផងមិនដែលជួប អត់ដែលឮឈ្មោះទេ ។

ឈុនលី ៖ ចុះតាម៉ុក?

ណាំ ៖ ឮតាម៉ុក អៀង សារី ប៉ុល ពត....នួន ជា ប៉ុនមិនដែលបានឃើញមុខ ឮតែឈ្មោះ ។

ឈុនលី ៖ ឮតែឈ្មោះ?

ណាំ ៖ បាទ!

ឈុនលី ៖ ចុះអៀង សារី ស្គាល់ម៉ង?

ណាំ ៖ អៀង សារី គាត់មិនស្គាល់ទេ ប៉ុនស្គាល់តាមរយៈកូនគាត់ៗចេញចូល ។

ឈុនលី ៖ អៀង វុធ?

ណាំ ៖ បាទ! អៀង វុធ ។

ឈុនលី ៖ កាលនឹងគាត់ធ្វើអីគេអៀងវុធនឹង?

ណាំ ៖ អត់ដឹងធ្វើអីទេ ដូចអត់ធ្វើអីផង មិនដែលឃើញធ្វើអី ខ្ញុំអត់ដឹងថាធ្វើអី ប៉ុន្តែការងារគាត់ជាមួយឪពុកម្តាយគាត់ដឹងម៉េច ។

ឈុនលី ៖ ចុះពួដល់ពេលសមាហរណកម្មហើយអីចឹង ការរស់នៅរស់ពួយ៉ាងម៉េចទៅ?

ណាំ ៖ អត់អីទេ វានៅធ្វើស្រែធ្វើចំការចឹងទៅ ។

ឈុនលី ៖ បានដីស្រែ ដីអីចឹងទៅ?

ណាំ ៖ បាទ! បានដីស្រែដីចំការ ។

ឈុនលី ៖ ចឹងគេចាប់ផ្តើមចែកដីប្រជាជនក្រោយសមាហរណកម្មទេ?

ណាំ ៖ បាទ! សមាហរណកម្មទេ ។

ឈុនលី ៖ គេចែកម៉េចវិញ ប៉ុន្មានៗម៉ែត្រ?

ណាំ ៖ គេចែកតាមគ្រួសារ ។

ឈុនលី ៖ ប៉ុន្មានម៉ែត្រ?

ណាំ ៖ បាទ! ដីចំការតាមគ្រួសារដីចំការក្នុងម៉ាហិចតា៣-៤ហិចតាម្នាក់ម៉ាគ្រួសារតាមកូនតិច កូនច្រើន ។

ឈុនលី ៖ កាលនឹងពូដឹងទេ មានប៉ុន្មានគ្រួសារ?

ណាំ ៖ អត់ដឹងទេ ច្រើន ដឹងប៉ុន្មានគ្រួសារ ។

ឈុនលី ៖ ប្រហែលប៉ុន្មាន បើតាមពូស្មាន?

ណាំ ៖ ហ៎! ស្មានប្រហែល៥០០-៦០០គ្រួសារ ។

ឈុនលី ៖ ដល់ពេលចឹងឈប់ច្បាំងឈប់អី គ្រាន់ថាយើងទៅធ្វើទាហានជាមួយគ្នាទៅ ហើយប្រពន្ធកូននៅធ្វើអី?

ណាំ ៖ នៅឯង ប្រពន្ធកូននៅធ្វើស្រែជាមួយគ្នា ការងាររកស៊ីធម្មតា ។

ឈុនលី ៖ ចុះដល់ពេលត្រូវរូវគ្នាភ្លាមៗអីចឹង ដូចយើងទាហានដូចគ្នាចឹង យើងរាប់អានគ្នាម៉េចទៅធ្លាប់ទៅច្បាំងគ្នា ។

ណាំ ៖ មានអីនៅជាមួយគ្នា ។

ឈុនលី ៖ ធ្លាប់តែច្បាំងគ្នា?

ណាំ ៖ បាទ! រាប់អានគ្នានៅកងគ្នាប្រេបូកប្រេបល់ដូចធម្មតាស្រឡាញ់គ្នាដូចធម្មតាទៅ ។

ឈុនលី ៖ លែងអីទៅ?

ណាំ ៖ បាទ! មានអី ។

ឈុនលី ៖ ពូសប្បាយចិត្តទេ កាលហ្នឹង?

ណាំ ៖ បាទ! សប្បាយចិត្ត... ។

ឈុនលី ៖ ហើយអាពេលក្នុងសម័យអត់ទាន់សមាហរណកម្ម ពូដែលចង់ចូលសមាហរណកម្មហ៎?

ណាំ ៖ ចង់ ចិត្តចង់ មិនចង់ឲ្យកើតសង្គ្រាមចិត្តចង់ មិនចង់ច្បាំងតែម្ដងនិយាយរួម ។

ឈុនលី ៖ ពិបាកពេក?

ណាំ ៖ បាទ! ពិបាកម៉ាសព្វ ។

ឈុនលី ៖ តែពូមានដែលគិតថាចង់រត់ទៅមុនគេ ទៅម្នាក់ឯង ដែរ?

ណាំ ៖ ចិត្តចង់ ប៉ុនតែទៅខ្លាចគេធ្វើបាប ។

ឈុនលី ៖ ពូនិយាយថាខ្មែរក្រហមអត់ឲ្យទៅម៉េច?

ណាំ ៖ ហ្នឹងហើយ អត់ឲ្យទៅ គេឃាត់មិនឲ្យយើងទៅទេ គ្រាន់ថាបើយើងទៅគេខ្លាចធ្វើបាប ។

ឈុនលី ៖ ចុះមានដែលមានអ្នកណាគេដែលទៅហើយគេចាប់បានចាប់អី?

ណាំ ៖ មាន មិនដែលឮថាអ្នកណាថាទៅផង តែទៅបាត់ៗហើយអត់មាន ។

ឈុនលី ៖ អត់ដែលឮថាចាប់បាន?

ណាំ ៖ បាទ! អត់ដែលឮចាប់បាន ។

ឈុនលី ៖ ចឹងបានន័យថាមានអ្នករត់ចូលដែរ?

ណាំ ៖ បាទ! មាន ។

ឈុនលី ៖ តែពូអត់ហ៊ាន?

ណាំ ៖ អត់ហ៊ានខ្លាចគេរហូត មិនសូវហ៊ានដូចគេ ។

ឈុនលី ៖ ពូដែលទៅលេងស្រុកកំណើតទេ តាំងពីហ្នឹងមក?

ណាំ ៖ ទៅៗខ្ញុំទៅញឹកដែរ ។

ឈុនលី ៖ ឥឡូវនឹងទៅញឹក?

ណាំ ៖ បាទ! ទៅ៣-៤ដងហើយ ។

ឈុនលី ៖ ហើយដល់ពេលទៅដល់ចឹង អ្នកដូចបងប្អូនអីចឹង ឥឡូវឪពុកម្តាយពូនៅតើ?

ណាំ ៖ ឪពុកស្លាប់ហើយ នៅតែម្តាយ ។

ឈុនលី ៖ គាត់ស្លាប់ឆ្នាំណា?

ណាំ ៖ គាត់ស្លាប់៧៩ ។

ឈុនលី ៖ ដោយសារអីគេ?

ណាំ ៖ ដោយសារគាត់រត់ អឺ!គាត់ទៅនៅស្រុកវិញ គាត់ឈឺ ។

ឈុនលី ៖ ចុះគាត់ អាពេលពូមកនៅនឹង គាត់ដឹងគេថាពូមកនៅនឹង?

ណាំ ៖ អត់ដឹង ទាល់សមាហរណកម្មបានដឹង ។

ឈុនលី ៖ ហើយគាត់ដែលហៅពូត្រឡប់ទៅនៅនឹងវិញអត់?

ណាំ ៖ អត់ទេ បើទៅក៏ខ្ញុំមានផ្ទះមានអីនៅក៏គេត្រូវគ្នាអស់ហើយ ។

ឈុនលី ៖ គាត់អត់ហៅទេ?

ណាំ ៖ បាទ!

ឈុនលី ៖ ហើយគាត់មានខឹងទេ ពូចូលជាមួយខ្មែរក្រហម?

ណាំ ៖ គាត់ខឹងដែរ ម្តាយខ្ញុំ ។

ឈុនលី ៖ ម៉េចបានខឹង?

ណាំ ៖ ចុះបើវាបែកគ្នា ខ្ញុំថាបើដឹងទៅរកម៉េណា បើគេមេកងមេអីគេចេះប្រមូលមកឲ្យមកតាមកង តាមក្រុម ខ្ញុំមិនដឹងទៅរកណា ។

ឈុនលី ៖ ចុះគាត់មានបន្ទោសពូទេ ថាម៉េចក៏មិនរត់ទៅណាផ្សេងទៅ ម៉េចចាំបាច់ចូលធ្វើខ្មែរក្រហម អីចឹង?

ណាំ ៖ គាត់អត់មាននិយាយចឹងផង.... គ្រាន់ថាគាត់ថា ។

ឈុនលី ៖ ចុះដល់ពេលជួបគ្នា?

ណាំ ៖ បានជួបអរ ។

ឈុនលី ៖ ជួបគ្នាចឹងទៅ គាត់និយាយប្រវត្តិគាត់អីអត់?

ណាំ ៖ បាទ! និយាយថា ។

ឈុនលី ៖ ហើយគាត់និយាយថាគាត់ស្អប់ខ្មែរក្រហមអត់?

ណាំ ៖ ស្អប់ គាត់និយាយ ។

ឈុនលី ៖ ស្អប់អត់ពូ?

ណាំ ៖ គាត់និយាយថាគាត់ស្អប់ ។

ឈុនលី ៖ ហើយពូមានអារម្មណ៍ម៉េចទៅ បើពូចូលខ្មែរក្រហមដែរ?

ណាំ ៖ អត់មានថាម៉េចទេ វាខ្ញុំអត់មាត់វាអត់មានអារម្មណ៍ថាម៉េចទេ ធ្វើម៉េចវាការខុសការត្រូវ ។

ឈុនលី ៖ ហើយគាត់ក៏អត់បន្ទោសដែរ?

ណាំ ៖ បាទ! អត់បន្ទោសទេ ។

ឈុនលី ៖ ចុះអ្នកស្រុកអ្នកភូមិ គេដឹងថាពូខ្មែរក្រហម?

ណាំ ៖ ដឹងៗថានៅធ្វើខាងខ្មែរក្រហម ។

ឈុនលី ៖ ហើយគេស្អប់ គេខឹងអត់?

ណាំ ៖ គេអត់ខឹងទេ ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ ព្រោះខ្ញុំ ម៉េចខឹងបើខ្ញុំបែកគ្នានៅឆ្នាំ៧៩មានស្អីត្រូវខឹងខ្ញុំកើត ខ្ញុំនៅកងចល័ត ខ្ញុំពីសម័យ ៧៩ខ្ញុំមានបានធ្វើអីនឹងគេ អត់មានអីត្រូវ ។

ឈុនលី ៖ តែគេអត់មានអីដូចថាគេខឹង គេសងសឹងអី?

ណាំ ៖ បាទ! អត់ទេ ខ្ញុំអត់មានធ្វើអីនឹងគេទេ គ្រាន់តែមកដោយចេតនាមកដោយគេបង្ខំតាមអង្គភាព៧៩ មកនៅតាមជាយដែននេះ ។

ឈុនលី ៖ ម៉េចបានពូដឹងថាអត់មានគេខឹង?

ណាំ ៖ ដឹងម៉េច ប៉ុន្ដែខ្ញុំវាមិនបានធ្វើអី កាលសម័យនោះយើងធ្លាប់នៅធ្វើកងចល័តរែកដីរែកអីទាំងអស់គ្នាក្មេងៗ ដឹងទាំងអស់គ្នាសម័យ៧៩ ។ ហើយខ្ញុំទើបហ្នឹងសម័យវៀតណាមចូលមកៗនៅតាមជាយដែន គេក៏អត់ដឹងខឹងអីផង ថាយើងទៅធ្វើទាហានខ្មែរក្រហមធម្មតា ច្បាំងជាមួយវៀតណាម ហើយនឹងខ្មែរគ្នាឯងៗ គេថាចឹង គេមានខឹងអី គ្រាន់តែឈ្មោះខ្មែរក្រហមហ្នឹងវាអតីតតាំងពីឆ្នាំ៧៣ ៧៤ ៧៥មកនឹង ដល់ចឹងវាមានដំណាក់កាលវាចឹងៗ ឈ្មោះថាខ្មែរក្រហមនឹង ប៉ុន្ដែខ្មែរក្រហមខ្លះដូចខ្ញុំនោះមកចូលឆ្នាំ៧៩ហើយ មានស្អីបានទៅធ្វើអីសម័យ៣ឆ្នាំម៉េចកើតអត់ទេ ។ សម័យ៧៩នោះវាចាប់ពី៨០ ៨១ ៨២ អត់មានអីគេ គ្រាន់តែមកនៅច្បាំងជាមួយខ្មែរគ្នាឯងប៉ុននឹង អត់មានទាន់មកធ្វើអីនយោបាយក្នុងប្រទេសទេ អត់មានទេ គ្រាន់តែប៉ុននឹងទេ គេអត់មានខឹងអីផង ។

ឈុនលី ៖ ចុះពូដឹងទេថា ប្រជាជនទូទៅគេខ្លាចពាក្យខ្មែរក្រហម?

ណាំ ៖ គេខ្លាចៗដោយបុគ្គលទេ តាមខ្ញុំគិត ។

ឈុនលី ៖ ម៉េចបានពូគិតចឹង?

ណាំ ៖ គិតថាបុគ្គលខ្លះគេដឹង គេអត់ខ្លាច បុគ្គលខ្លះគេមិនដឹងគេខ្លាចមែន បើគេអ្នកដឹកគេអត់ខ្លាច ។

ឈុនលី ៖ ចុះចំពោះពូផ្ទាល់ក៏ធ្លាប់ធ្វើការហត់នៅសម័យហ្នឹងដែរ ពូខឹងខ្មែរក្រហមអត់ពីដំបូងមក?

ណាំ ៖ ខឹង ហ៊ើ!ខឹង ខ្ញុំខឹងខ្មែរក្រហមហើយសម័យនឹង ខ្ញុំរែកដីហត់នៅកងចល័តអត់បាយអត់អីដែរឆ្នាំ៧៥ហ្នឹង អឺ!៧៩ហ្នឹង អឺ!៧៥ហ្នឹង ។ អត់បាយអត់អីនៅរែកតែដី ម៉ាថ្ងៃគ្មានពេលឈប់ខឹងដែរនឹង ប៉ុនមិនដឹងធ្វើម៉េចដល់ចឹងមកចឹងនិយាយអត់កើត ។

ឈុនលី ៖ ចុះដល់ពេលស្អប់ខ្មែរក្រហម ដល់គេជម្លៀសមកៗនឹងគេដែរ?

ណាំ ៖ មកនឹងគេដែរ ចុះគេដេញមកទាំងរ៉ូងគោ ដូចរ៉ូងគោ ។

ឈុនលី ៖ មិនដឹងធ្វើម៉េច?

ណាំ ៖ បាទ! មិនដឹងធ្វើម៉េច ចោលបន្ទីចោលចបនឹង ពេលនឹងគេថាអូ!វៀតណាមមកហើយវៀតណាមចូលហើយៗ ដល់គេមេកងមេក្រុមគេជម្លៀសមកបណ្ដោយ ដឹកទាំងឡានៗចូលមកទម្លាក់ព្រំដែនទាំងអស់ ។

ឈុនលី ៖ ពេលនឹងពូអន់ចិត្តទេ?

ណាំ ៖ អន់ អូ! សម័យនោះខ្ញុំយ៉ាប់ជាងគេស៊ីតែបបរទេ នៅកងចល័តហូបអត់បានឆ្អែត ។

ឈុនលី ៖ អត់ទេ អាពេលពូចូលជាមួយខ្មែរក្រហមនឹង ដូចខឹងរបៀបថាសត្រូវយើងពីមុនដែលគិតចឹងអត់?

ណាំ ៖ បាទៗ គិតចឹងដែរ ដំបូងប៉ុនយូរៗទៅឈប់គិតអស់ ដល់លំបាកនេះ ។

ឈុនលី ៖ ធ្លាប់នៅជាមួយគ្នា?

ណាំ ៖ បាទ! ធ្លាប់នៅជាមួយគ្នាអត់គិតចឹង ។

ឈុនលី ៖ ពូចុះដល់ពេលមកដល់ឥឡូវពូគិតថា ពូស្រឡាញ់ទឹកដីនេះទេ?

ណាំ ៖ ស្រឡាញ់ ខ្ញុំស្រឡាញ់ ខ្ញុំអត់ចង់ឲ្យកើតសង្គ្រាម ហើយខ្ញុំនឹងចង់ការពារទឹកដីខ្មែរឲ្យបាន ខ្ញុំនឹងចង់ការពារទឹកដីខ្មែរឲ្យបាន ខ្ញុំអត់ចង់ឲ្យបាត់បង់ទឹកដីនេះទេ ។

ឈុនលី ៖ ហើយដល់ពេលពូទៅផ្ទះទៅលេងស្រុកអីចឹង ហើយនឹងពេលពូត្រឡប់មកវិញ ពូនឹកមួយណាជាង? ទៅស្រុកអីចឹងនឹកកន្លែងនេះទេ?

ណាំ ៖ នឹកផ្ទះនេះជាង ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ ព្រោះខ្ញុំ ផ្ទះទឹកដីយើងនៅនេះដូចគ្នា ផ្ទះដីយើងនៅនេះ ។

ឈុនលី ៖ ហើយបើឲ្យពូទៅនៅនោះនៅកើតអត់?

ណាំ ៖ នៅអត់កើត អត់មានមុខរបរអីធ្វើ ។

ឈុនលី ៖ ចុះបើយើងគិតថា ពេលយើងមកនៅដំបូងក៏អត់មុខរបរ ដល់ពេលយើងទៅនោះចាប់ផ្ដើមសារថ្មីដូចគ្នាទៅ?

ណាំ ៖ អត់ទេ ទៅវាលំបាកតិច ដល់នេះយើងមានមុខរបរហើយ អត់ទៅកើតទេ ។

ឈុនលី ៖ មិនអាចទៅបានទេ?

ណាំ ៖ បាទ!

ឈុនលី ៖ ដូចជាប់ចិត្តជាមួយទឹកដីនៅនេះ?

ណាំ ៖ ជាប់ចិត្ត ទឹកដីនៅនេះបើទៅអស់ អ្នកណានៅតាមព្រំដែន អ្នកណាការពារព្រំដែននេះ អត់មានអ្នកណាការពារព្រំដែនទេ ណាអត្តភាពកង៏ទ័ពនៅនេះផង នៅធ្វើទាហាននៅនេះផងទៅអត់បាន ។

ឈុនលី ៖ ចុះពូដូចពូនៅក្នុងទាហានខ្មែរក្រហមអីចឹង ដូចថាការចិញ្ចឹមកូនចៅអី ពូអប់រំបែបម៉េចទៅអប់រំកូន ប្រដៅកូនអីចឹង បែបម៉េច?

ណាំ ៖ អប់រំកូនឲ្យតែប្រឹងរៀនសូត្រ អត់មានឲ្យប្រឹងរៀនអីខុសពីការឲ្យកូនខំប្រឹងរៀនសូត្រឲ្យមានការចេះដឹង ឲ្យមានការយល់ដឹងច្រើនកុំឲ្យមានការភ័ន្តច្រឡំ ដើម្បីមើលការខុសត្រូវតែប៉ុននឹង ......។ ហើយណែនាំទៅថាទៅមុខទៅ ប្រទេសជាតិវារីកចំរើន យើងត្រូវការចេះៗទៅ យើងត្រូវការធ្វើការងារក្រុមហ៊ុនធំៗអីក្នុងលក្ខណៈជាការងាររាជការអីទៅ អីក៏បានមានមុខមានមាត់ហើយ ។

ឈុនលី ៖ ហើយនៅនេះពូយល់ថា ពូរាល់ថ្ងៃពូរស់នៅបែបដូចថៃនៅនេះ?

ណាំ ៖ អត់ទេ ខ្ញុំថាអត់ដូច ។

ឈុនលី ៖ ម៉េចបានអត់ដូច?

ណាំ ៖ ខ្ញុំទស្សនៈខ្ញុំខុសគេ ខ្ញុំថាខ្ញុំមិនយករបៀបរបបថៃ ខ្ញុំទស្សនៈខ្ញុំ ជំហរខ្ញុំថាមិនយករបៀបរបបថៃ រស់នៅដោយរបៀបរបបខ្មែរ មិនចូលចិត្តរបៀបរបបថៃ ។

ឈុនលី ៖ មើលទៅម្ដុំនេះដូច មើលទៅដូចរបៀបខ្មែរតើ បើភូមិផ្សេងៗទៀត វាចង់កាត់ថៃម៉េចចឹង?

ណាំ ៖ បាទ!ខ្ញុំគិតចឹងម៉ង ជាជំហររបស់ខ្ញុំៗមិនយកទំនៀមទំលាប់ថៃ របៀបរបបថៃ គិតអីក៏របៀបរបបខ្មែរ ។ ខ្ញុំថាកូនចៅខ្ញុំមិនដែលចង់ឲ្យទៅរៀនថៃ ។

ឈុនលី ៖ ចុះពូមកដល់ឥឡូវហ្នឹង ពូគិតថាប្រជាជនធម្មតាគេស្អប់ខ្មែរក្រហម គេនៅតែខឹងខ្មែរក្រហមអត់?

ណាំ ៖ នៅតែខឹង ។

ឈុនលី ៖ ពូគិតថាចឹង?

ណាំ ៖ បាទ!

ឈុនលី ៖ ហើយដូចពូធ្លាប់ធ្វើជាខ្មែរក្រហមដែរអីចឹង ពូគិតថាចង់ឲ្យអ្នកទាំងអស់គ្នានឹង ឈប់ខឹងជាមួយខ្មែរក្រហមទេ?

ណាំ ៖ ចង់ដែរនឹង ចង់ថាកាលកន្លងហួសហើយដូចយើងវាមិនចង់ឲ្យខឹង ខឹងឲ្យចំគោលដៅខឹងគេ ធ្វើម៉េចបើអ្នកធ្វើធំៗវាងាប់អស់ គេរត់ចោលអស់ តែយើងទៅខឹងម៉េច អាគ្នាក្រោមៗគ្នាឯងអត់ដឹងអី ខឹងអី គ្រាន់តែមានតែឈ្មោះនៅខាងខ្មែរក្រហមខឹងអីចឹងក៏វាមិនត្រឹមត្រូវ ។

ឈុនលី ៖ ហើយចឹងធ្វើម៉េច បើតាមគំនិតពូៗចង់ធ្វើម៉េចដើម្បីឲ្យគេឈប់ខឹង?

ណាំ ៖ មិនដឹងធ្វើម៉េចទេ នឹងគិតតាមទស្សនៈមនុស្សនីមួយៗមិនអាច ។

ឈុនលី ៖ បើតាមពូគិតខ្លួនឯង?

ណាំ ៖ ហ្នឹងគិតខ្លួនឯង មនុស្សមួយៗមិនអាច ខ្លះក៏គេដឹងទៅ គេមិនខឹងទៅ ខ្លះក៏គេមិនដឹងទៅក៏នៅតែខឹងនឹងយើង ព្រោះប្រជាជននៅទូទាំងប្រទេស ។ ឈ្មោះនៅតែឈ្មោះខ្មែរក្រហមវានៅជាប់អតីតមកហើយ វាត្រូវតែមានអ្នកខឹង និងអ្នកមិនខឹង ២នឹងខ្ញុំជឿជាក់ចឹង ។ ប៉ុន្តែ អ្នកដែលខឹង អ្នកដែលមិនខឹងក៏វាស្មើរស្មើគ្នា ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ បានៗចឹងបានខ្ញុំថា ខ្ញុំគិតឃើញចឹងត្រង់ថា ខ្លះគេគិតថាប្រជាជនខ្លះគេគិតថាខ្លះវាកន្លងផុតហើយវាគំនិតខឹងគ្នាអតីតកាលក៏ខឹងមិនកើត ខឹងៗអាអ្នកមេកំពូលធំៗនេះបានត្រូវខឹង ដូច

ថាអ្នកធ្វើការនៅជាមួយគ្នាអា.....ឈ្មោះថានៅប៉ែកខ្មែរក្រហមខ្លះ ប្រជាជនក៏នៅតំបន់ខ្មែរក្រហមដែរ ហើយទៅខឹងគ្នាម៉េចប្រជាជន អានឹងក៏វាមិនត្រឹមត្រូវ ដល់ហើយគិតឃើញចឹង ។

ឈុនលី ៖ ចុះពូ ខ្ញុំឧទាហរណ៍ថា បើសិនជាពូឃើញមនុស្ស៤-១០នាក់ គេនិយាយគ្នារឿងខ្មែរក្រហម ហើយថាគេស្អប់ខ្មែរក្រហមអីចឹង ហើយពូនឹងធ្វើម៉េចទៅ បើពូនៅនឹងដែរ ពូឈរមើលគេហ្នឹង?

ណាំ ៖ បាទ!នេះហ្នឹងហើយ ខ្ញុំដើរស្តាប់ទៅ និយាយរួមយើងអត់និយាយកាត់ ។

ឈុនលី ៖ អត់អាចតវ៉ាបាន?

ណាំ ៖ អត់អាចតវ៉ាបាន យើងអត់និយាយជាមួយគាត់ យើងមាននិយាយថាកាលកន្លងហួស ធ្វើម៉េចវាកាលសំខាន់យើងមិនបានទៅធ្វើអីខុសទេ ប៉ុន្តែយើងគ្រង់ថាឈ្មោះហ្នឹងវាហួសទៅហើយ ខ្ញុំមិនចង់រំលឹកចង់ពុ្ត យើងគ្រាន់ថាចឹងបាន គេនៅដាក់ចិត្តយើង ។ ប៉ុនតាមខ្ញុំយល់ទេ ថារឿងនឹងត្រូវតែមាន ដូចមានអ្នកខឹង មានអ្នកមិនខឹង ខ្ញុំជឿជាក់ចឹង ទស្សនៈនឹង ។ ទោះបីទៅជំនាន់ណាក៏នៅតែខឹង នៅតែមានឈ្មោះខ្មែរក្រហមនៅតែមានគំនិតអ្នកខឹងដូចគ្នា តែតិចច្រើន ខ្ញុំមិនដឹង ព្រោះអ្នកអនុវត្តសង្គម ដឹកនាំសង្គមនីមួយៗ តែខុសគឺត្រូវជាប់ក្នុងប្រវត្តិសាស្ត្រា ។ ដល់ហើយសៀវភៅក្នុងប្រវត្តិសាស្ត្រគេចេះចែងទៅ ហើយដល់ជំនាន់ក្រោយគេចេះឃើញចេះមើលចេះឃើញ ម្ល៉ោះហើយចេះខឹង ។ ហ្នឹងចឹង ។

ឈុនលី ៖ ចុះ បើតាមគំនិតពូៗគិតថា ប្រជាជនធម្មតា ហើយជាមួយពូខាងទាហានខ្មែរក្រហមអីចឹង ពីគិតថាបើចង់ផ្សះផ្សាជាមួយគ្នា គួរតែយើងរស់នៅជិតគ្នា ឬមួយក៏រស់នៅឆ្ងាយពីគ្នាក៏អាចផ្សះផ្សាបាន?

ណាំ ៖ សូម្បីតែរឿងនឹង បើយើងហៅថាមានជំនឿថាផ្សះផ្សា ទោះបីឆ្ងាយក៏យើងផ្សះផ្សាក៏យើងត្រូវផ្សះផ្សាបាន នៅឆ្ងាយក៏បាន ខ្ញុំជឿជាក់ចឹង ។

ឈុនលី ៖ តាមគំនិតពូ?

ណាំ ៖ បាទ!

ឈុនលី ៖ ចឹងបើនៅឆ្ងាយធ្វើម៉េចផ្សះផ្សាបាន?

ណាំ ៖ ឆ្ងាយ ទៅវិញទៅមក ទៅលេងទៅវិញទៅមក គឺបាន ទៅបាន ។

ឈុនលី ៖ ចឹងឧទាហរណ៍ថាពូទៅលេងស្រុកខ្លួនឯងអីចឹង អានឹងអាចថាជាការផ្សះផ្សាដែរ?

ណាំ ៖ បាទ! អាហ្នឹងជាការផ្សះផ្សា ។

ឈុនលី ៖ ពេលដែលយើងទៅជជែកគ្នាចឹង?

ណាំ ៖ បាទ! ទៅដដែកគ្នាលេងការផ្សេះផ្សា ។

ឈុនលី ៖ ចឹងពេលពូទៅលេងស្រុកអីចឹង គេគាំទ្រនៅតែរាប់អានយើង?

ណាំ ៖ បាទ! គេអត់មានអីផងប្រជាជនភូមិខ្ញុំ ទាំងអស់ វាមិនដឹងទេ គេមិនយកអីទេ ។

ឈុនលី ៖ ចុះពូថាអីគេមុន្នីនឹងគាត់ហ្នឹង គាត់គ្រប់គ្រងហ្នឹង ក្រោយមកគាត់ធ្វើអីទៀតទៅ ធ្វើចៅហ្វាយស្រុកបន្ទាប់ពីសមាហរណកម្មទៅ?

ណាំ ៖ បាទ! គាត់ធ្វើចៅហ្វាយស្រុក ។

ឈុនលី ៖ ចៅហ្វាយស្រុកនឹងមុនសមាហរណកម្ម ឬក៏ក្រោយ?

ណាំ ៖ មុន ក្រោយសមាហរណកម្មហើយបានធ្វើ ។

ឈុនលី ៖ អ្នកណាកាន់ទៀត ក្រោយសមាហរណកម្ម ក្រោយនឹងអ្នកណាគេធ្វើសមាហរណកម្ម?

ណាំ ៖ ក្រោយសមាហរណកម្មគាត់ធ្វើចៅហ្វាយស្រុក ឈឹម មុន្នី ។

ឈុនលី ៖ មុន្នីហ្នឹង?

ណាំ ៖ បាទ!

ឈុនលី ៖ ចុះទេព ខុនណាល់?

ណាំ ៖ ទេព ខុនណាល់គាត់ធ្វើក្រោយ ។

ឈុនលី ៖ ក្រោយឆ្នាំណា?

ណាំ ៖ ទេព ខុនណាល់ ធ្វើទើបបានប៉ុន្មានឆ្នាំ ៤ឆ្នាំហើយ ។

ឈុនលី ៖ ៤ឆ្នាំហ្នឹង?

ណាំ ៖ បាទ! ហ្នឹងហើយ ទេព ខុនណាល់ ។ ដល់នេះឈឹម មុន្នីធ្វើ តាំងពីផ្តាច់ខ្លួនមកគាត់ធ្វើ ផ្សេះផ្សាមក ក៏ផ្តាច់ខ្លួនសម័យផ្តាច់ខ្លួនគាត់ធ្វើ... ។

ឈុនលី ៖ ៩៧មក?

ណាំ ៖ កាលពីដើមមកគាត់ធ្វើកងទ័ពទេ ។

ឈុនលី ៖ កងទ័ពអីគេ?

ណាំ ៖ កងទ័ពដូចគ្នា កងទ័ពទាហាន ។

ឈុនលី ៖ តែគាត់មេធំ?

ណាំ ៖ ធ្វើទាហានធម្មតា មិនមែនមេធំទេ គាត់មេតូច ។

ឈុនលី ៖ ដូចពូដូចអីដែរ?

ណាំ ៖ បាទ!មេតូចដែរហ្នឹង មិនមែនមេធំទេ ។

ឈុនលី ៖ តែគេមានឋានៈលើយើង?

ណាំ :	បាទ! មេ បើយុទ្ធជន ។

ឈុនលី : យុទ្ធជនម៉េង?

ណាំ :	បាទ!

ឈុនលី : ចុះពូខ្ញុំចង់សួររឿងតុលាការខ្មែរក្រហមតិច ពូថាគាំទ្រឲ្យមានការកាត់ទោសខ្មែរក្រហមដែរ?

ណាំ :	បាទ!

ឈុនលី : បើតាមគំនិតពូ គិតថាអ្នកណាគេគួរតែត្រូវកាត់ទោសអីចឹង?

ណាំ :	តាមគំនិតដែលត្រូវកាត់ទោស ។

ឈុនលី : មេធំៗអីចឹង?

ណាំ :	អូ! ហ្នឹង ត្រូវកាត់ដែលមេណាមេធំអស់លេខ ។

ឈុនលី : ចុះពូមានដឹងទេថាអ្នកណាខ្លះដែលត្រូវបានគេកាត់ទោសរាល់ថ្ងៃ?

ណាំ :	ដឹងៗថាតាឌុច ដឹងកាត់ទោសរួចហើយ ។

ឈុនលី : ឌុច ហើយអ្នកណាទៀត?

ណាំ :	អេ! អៀង សារី ហើយនឹងខៀវ សំផន, ហើយនឹងនួន ជា ដឹងថាគេកាត់ទោស ។

ឈុនលី : ចុះដូចពូធ្លាប់រស់នៅជាមួយអៀង សារីអីចឹង ក្រោយការគ្រប់គ្រងគាត់ ពូចង់ឲ្យគេកាត់ទោសគាត់ដែរ?

ណាំ :	បាទ!

ឈុនលី : ដូចអៀង សារីអីចឹង?

ណាំ :	ហ៊ើ! អានឹងអត់ដឹងទេ តែអ្នកណាខុសអ្នកនឹងត្រូវកាត់ទោសតាមច្បាប់របស់តុលាការ ។

ឈុនលី : តែគាំទ្រឲ្យមានដែរ?

ណាំ :	បាទ!

ឈុនលី : មើលតាមទូរទស្សន៍?

ណាំ :	បាទ! ខ្ញុំមើលតាមទូរទស្សន៍បានដឹង ។

ឈុនលី : ខស្សាហ៍មើលដែរ ឲ្យតែមានរឿងកាត់ទោសនឹង?

ណាំ :	អឺ! ខ្ញុំតាមដានមើល ។

ឈុនលី : ព្រោះយើងធ្លាប់នៅក្នុងរបបនឹងអីចឹង?

ណាំ :	គ្រាន់ក្នុង៧៩មក៨៧ វាប៉ុន្មានឆ្នាំ ។

ឈុនលី : ពូដឹងទេថា គេកាត់ទោសនឹងសម្រាប់តែខ្មែរក្រហមនៅក្នុងរបបណាមកអីចឹង?

ណាំ :	តាំងពីអឺ! របបឆ្នាំ៧០មកដឹង ។

ឈុនលី ៖ និយាយទៅពូតុលាការនឹង គេកាត់ទោសតែអ្នកដែលគ្រប់គ្រងខ្មែរក្រហមជំនាន់៧០គត់ អី!៧៥ដល់៧៩ ។

ណាំ ៖ បាទ! គេកាត់ត្រឹមនឹង ។

ឈុនលី ៖ ចុះដល់ពេលពូមកខ្ទង់៧៩មកឆ្ងាយទៀត ពីពីដំបូងពេលឮពីតុលាការ ពូដូចមានអារម្មណ៍ថាភ័យខ្លាចអត់?

ណាំ ៖ អត់ភ័យ ខ្ញុំអត់ចេះភ័យខ្លាច ។

ឈុនលី ៖ ព្រោះយើងធម្មតា?

ណាំ ៖ បាទ! ខ្ញុំប្រជាជនដើរនេះធម្មតា ខ្ញុំអត់ភ័យខ្លាចទេ ព្រោះអត់បានធ្វើអីនៅក្នុងអំឡុងនឹង អត់ដែលបានប្រឡូក មានតែគេធ្វើបាបខ្ញុំក្នុងអំឡុងនឹង ។ អំឡុងខ្ញុំនៅកុមារនៅតូច នៅកុមារវែកដី ខ្ញុំមានអីត្រូវខ្លាចអំឡុងនឹង ។ បើពី៧៩ ៨០មកដល់៩៧នេះខ្ញុំគ្មានអី ខ្ញុំវាអត់មាន គ្រាន់នៅទាក់ទិននៅក្នុងនយោបាយតិច ។ ខ្ញុំអត់ត្រូវខ្លាចទេ ។

ឈុនលី ៖ ចុះពីមានអីចង់ត្រូវបន្ថែមតិចទៀតទេ?

ណាំ ៖ អត់ទេ ខ្ញុំអត់មានចង់បន្ថែម ។

ឈុនលី ៖ ដូចមានកន្លែងណាខ្ញុំសួរអត់អស់ ពូចង់ប្រាប់បន្ថែម?

ណាំ ៖ អត់ទេ ខ្ញុំអត់មានអីទេ ខ្ញុំសុំឆ្លើយប៉ុននឹង ខ្ញុំដឹងរឿងខ្ញុំប៉ុននឹង ។

ឈុនលី ៖ ដឹងតែប៉ុននឹង?

ណាំ ៖ បាទ!

ឈុនលី ៖ ខ្ញុំឮថាគេលើកទំនប់ៗម៉ក់ហឹន ពូស្គាល់?

ណាំ ៖ អត់ស្គាល់ផង ។

ឈុនលី ៖ អត់ស្គាល់ផង ។

ណាំ ៖ មានមីនហើយនឹងចំការ........... ។

ឈុនលី ៖ ចឹងពូឥឡូវពូនៅធ្វើយុទ្ធជនដដែល គេហៅម៉េចវិញ?

ណាំ ៖ ខ្ញុំធ្វើនៅទាហានរាល់ថ្ងៃនេះ ។

ឈុនលី ៖ ចា៎! គេហៅម៉េចវិញ?

ណាំ ៖ អាហ្នឹងគេហៅយុទ្ធជននឹងអត់មានតួនាទីអី ។

ឈុនលី ៖ ម៉េចចឹង?

ណាំ ៖ ដូចកូនទាហានគេម៉ង... តែឥឡូវនេះខ្ញុំមកចូលធ្វើទាហានខាងរដ្ឋកម្ពុជា តាំងពីសមាហរណកម្មហ្នឹង សមាហរណកម្មហើយ ខ្ញុំធ្វើមេគេសក្តិ២ ។

ឈុនលី ៖ សក្តិ២?

ណាំ ៖ អឺ!

ឈុនលី ៖ នៅកងពលនៅណា?

ណាំ ៖ កងពល៥១ ។

ឈុនលី ៖ នៅស្រុកអីគេ?

ណាំ ៖ នៅស្រុកព្រះនេត្រព្រះ ។

ឈុនលី ៖ ស្រុកព្រះនេត្រព្រះ ខ្ញុំធ្លាប់ទៅដែរ ។

ណាំ ៖ បន្ទាយធំនៅនឹង ។

ឈុនលី ៖ ចុះពូនៅអានធំហ្នឹង?

ណាំ ៖ បាទ! នៅក្នុងនឹង ។

ឈុនលី ៖ ចុះដល់ពេលគេទៅព្រះវិហារពូអត់មានគេយកកងពលពីនេះទៅ?

ណាំ ៖ កងពល.......... ។

ឈុនលី ៖ ទាហានច្រើន?

ណាំ ៖ ទាហានម៉ាកងពល ។

ឈុនលី ៖ ប៉ុន្មាននាក់ម៉ាកងពល?

ណាំ ៖ ដឹងប៉ុន្មាននាក់ ជាង១ពាន់ជាង ។

ឈុនលី ៖ មានស្រី មានប្រុស?

ណាំ ៖ អត់ទេ ទាហានៗ ។

ឈុនលី ៖ មានស្រីអត់?

ណាំ ៖ ស្រីមានពេទ្យ ។

ឈុនលី ៖ ពេទ្យទាហាន ។

«ចប់»